# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ សុខ ហាក់ ភេទប្រុស អាយុ៥៧ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហម "យោធាកងពល៨០១"**

**ស្រុកកំណើតនៅភូមិចុងកោះ ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល**

**រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ចាន់ ប្រុញ**

**០០:២៨:៣២**

**១៤ទំព័រ**

ប្រុញៈ ខ្ញុំសុំជំរាបសួរពូសារថ្មី ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងមកប្រមូលចង ក្រងឯកសារពាក់ព័ន្ធរឿងជីវភាពរបស់ពូ ការរស់នៅរបស់ពូ ការឆ្លងកាត់របស់ពូសម័យ ខ្មែរក្រហម សម័យមកក្រោយ។ ការតស៊ូរបស់ពូពាក់ព័ន្ធរឿងការរហូតមកដល់រាល់ថ្ងៃ។ អត់ទោសលោកពូឈ្មោះអីគេ?

ហាក់ៈ ខ្ញុំឈ្មោះ សុខ ហាក់។

ប្រុញៈ ង្ហូន សុខហាក់?

ហាក់ៈ សុខ។

ប្រុញៈ សុខ ហាក់?

ហាក់ៈ បាទ!

ប្រុញៈ ឈ្មោះរបស់ពូសុខ ហាក់ អីចឹងតែម្តង ឬម៉េច?

ហាក់ៈ ត្រកូលរបស់តាខ្ញុំឈ្មោះ សុខ ខ្ញុំឈ្មោះហាក់។

ប្រុញៈ លោកពូអាយុប៉ុន្មានហើយ?

ហាក់ៈ ខ្ញុំ៥៧ហើយ។

ប្រុញៈ ពូមានស្រុកកំណើតនៅណាដែរ?

ហាក់ៈ ស្រុកស្អាង ខេត្តកណ្តាល ឃុំទឹកវិល។

ប្រុញៈ អីចឹងលោកពូរាល់ថ្ងៃរស់នៅនេះភូមិ-ឃុំអីគេ?

ហាក់ៈ ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ប្រុញៈ ប្រពន្ធពូឈ្មោះអីគេ?

ហាក់ៈ ឈ្មោះ ង៉ែត គូ។

ប្រុញៈ ពូមានកូនប៉ុន្មាននាក់ដែរ?

ហាក់: កូន៧នាក់ ។

ប្រុញ: ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហាក់: ប្រុស៣ ស្រី៤ ។

ប្រុញ: ពូរៀនសូត្រដល់ថ្នាក់ណាដែរ?

ហាក់: ខ្ញុំរៀនថ្នាក់ទី៩ចាស់ ។

ប្រុញ: ដល់ឆ្នាំណាពូឈប់រៀន?

ហាក់: ដល់រដ្ឋប្រហារ៧០ ។

ប្រុញ: ឈប់រៀនឆ្នាំ៧០?

ហាក់: ៧០ ។

ប្រុញ: ដល់ពេលឈប់រៀនហើយពូទៅណាវិញ?

ហាក់: ៧២ចូលធ្វើកងទ័ព ។

ប្រុញ: ចូលធ្វើនៅណាវិញ?

ហាក់: ធ្វើកងទ័ពរណសិរ្ស ។

ប្រុញ: ចូលនៅណាវិញ?

ហាក់: ចូលនៅស្រុកស្អាង ខេត្តកណ្ដាល ។

ប្រុញ: ពូចូលហ្នឹងពីណាអ្នកនាំពូចូល ឬក៏?

ហាក់: ចូលខ្លួនឯង ។

ប្រុញ: គេអំពាវនាវឬយ៉ាងម៉េច?

ហាក់: អត់មានអំពាវនាវទេ បើពួកលន់ នល់ ទំលាក់គ្រាប់បែកដាក់ផ្ទះ ឆេះផ្ទះ ឆេះស្រែចំការ ដើមឈើដំណាំ ឈឺចាប់ចូលតស៊ូ ។

ប្រុញ: ពូចូលម្នាក់ឯង ឬមានគេចូលជាមួយ?

ហាក់: ពីរនាក់ ។

ប្រុញ: ពីរនាក់ឈ្មោះអីគេ?

ហាក់: ឈ្មោះថុល គាត់ស្លាប់បាត់ហើយ ។

ប្រុញ: ហើយពេលចូលហ្នឹងពូនៅស្រុកស្អាងហ្នឹងដែរ ឬក៏?

ហាក់: នៅស្រុកស្អាង ខេត្តកណ្ដាលហ្នឹង ។

ប្រុញ: កាលហ្នឹងគេចាត់តាំងឲ្យពូធ្វើអីគេ?

ហាក់: ខ្ញុំធ្វើនីរសា ។

ប្រុញៈ នីរសារបស់ពីណាគេ?

ហាក់ៈ នីរសារបស់ឈ្មោះ គក ។

ប្រុញៈ គាត់?

ហាក់ៈ មេបញ្ជាការ ។

ប្រុញៈ គាត់ប្រធាន?

ហាក់ៈ បញ្ជាការអនុសេនាធំនៅតាមអង្គភាព ។

ប្រុញៈ អង្គភាពអីគេ?

ហាក់ៈ អង្គភាព១៨ នៅ៤២ ។

ប្រុញៈ កងពល ឬកងវរៈ?

ហាក់ៈ កងពលកើតក្រោយទេ ។

ប្រុញៈ អីចឹងកាលហ្នឹងមានត្រឹមវរៈទេ?

ហាក់ៈ វរៈ ហើយនិងវរសេនាធំ ហើយនិងតំបន់ មិនទាន់បង្កើតកងពលទេ ។

ប្រុញៈ វរសេនាធំ អីចឹងគាត់ហ្នឹងអនុ?

ហាក់ៈ គាត់វរសេនាតូច ។

ប្រុញៈ វរសេនាធំពីណាគេ?

ហាក់ៈ វរសេនាធំឈ្មោះ យឹន គាត់ស្លាប់បាត់ហើយ ។

ប្រុញៈ ចុះមានពីណាធំជាង យឹន ទៀត?

ហាក់ៈ ធំជាង យឹន ទៀតមានសេនាធិការគេ ។

ប្រុញៈ ឈ្មោះអីគេ?

ហាក់ៈ ភ្លេចហើយ គាត់ស្លាប់បាត់អស់ហើយជំនាន់ហ្នឹង ។

ប្រុញៈ ពូធ្វើដល់ឆ្នាំណា?

ហាក់ៈ ខ្ញុំធ្វើរហូតដល់៩៣ខ្ញុំឈប់ធ្វើ ។

ប្រុញៈ ឥឡូវខ្ញុំសួរមួយជំណាក់សិន មុន៧៥សិន ។ ៧២ពូចូលធ្វើទ័ពហើយ ហើយក៏ធ្វើនីរសាដែរ?

ហាក់ៈ បាទ!

ប្រុញៈ ចុះ៧៣?

ហាក់ៈ ៧៣ក៏នៅក្នុងហ្នឹងដែរ ។

ប្រុញៈ ដល់ចិតប៉ុន្មាន?

ហាក់៖ រហូតដល់៧៥ បែកភ្នំពេញហើយ ។

ប្រុញ៖ អីចឹងពូនៅស្អាងរហូតដល់៧៥ ?

ហាក់៖ ៧៥ រំដោះភ្នំពេញហើយបានមករតនគិរី ។

ប្រុញ៖ ចូល៧៥ ហើយគេបញ្ជូនពូទៅរតនគិរី?

ហាក់៖ បាទ!

ប្រុញ៖ នៅក្នុងកងពល?

ហាក់៖ កងពល៨០១ ។

ប្រុញ៖ ពីណាគេគ្រប់គ្រងកងពលហ្នឹង?

ហាក់៖ កែវ សារឿន ។ កែវ សូសារឿន គាត់ស្លាប់អស់ហើយ ។

ប្រុញ៖ ពូមកហ្នឹងគេចាត់តាំងឲ្យពូធ្វើអីគេកាលហ្នឹង?

ហាក់៖ ខ្ញុំនៅមន្ទីរនៅតែក្រោយទេ គេឲ្យខាងនេសាទម្ដង រកត្រី ។

ប្រុញ៖ គេចាត់តាំងពូមានឋានៈអីគេ?

ហាក់៖ អត់មានឋានៈអីទេ មួយកងវរសេនាធំអីចឹងគេឲ្យខ្ញុំ៤-៥នាក់រកត្រីចិញ្ចឹមកងទ័ព ។

ប្រុញ៖ អីចឹងពូនៅកងវរសេនាធំអីគេ?

ហាក់៖ វរសេនាធំ៨១ ខាងនេសាទ រកម្ហូបឲ្យគេ ។

ប្រុញ៖ ពីណាគេប្រធានវរសេនាធំ?

ហាក់៖ វរសេនាធំហ្នឹងតាហ៊ិន តែឥឡូវគាត់ស្លាប់អស់ហើយ ។

ប្រុញ៖ ហ្នឹងក្នុងឆ្នាំណា? បើពូមកធ្វើក្នុងវរសេនាធំ៨១ហ្នឹងចន្លោះឆ្នាំណាដល់ឆ្នាំណា?

ហាក់៖ ៧៦-៧៧-៧៨ ។

ប្រុញ៖ ៣ឆ្នាំពេញ?

ហាក់៖ បាទ!

ប្រុញ៖ ក្រោយពីហ្នឹងមកពូធ្វើអីទៀត?

ហាក់៖ ក្រោយពីហ្នឹងមកខ្ញុំបើកឡាន ។

ប្រុញ៖ បើកឡានឲ្យពីណាគេ?

ហាក់៖ បើកឡានឲ្យមន្ទីរ ដឹកស្បៀង ។

ប្រុញ៖ ឆ្នាំណាដែលពូ?

ហាក់៖ ៩២ បន្ទាប់ពីហ្នឹងមក ៧៩ ។

ប្រុញ៖ ៧៩-៨០-៨១-៨២-៨៣រហូតមក ពូធ្វើអីគេ?

ហាក់: បើកឡានឲ្យគេ បើកឡានដឹកម្ហូប ដឹកស្បៀង ដឹកអង្ករ ។

ប្រុញ: ៨០ មកបើកឡាន?

ហាក់: បាទ!

ប្រុញ: បើកឡានឲ្យខាងណា?

ហាក់: ឲ្យវរសេនាធំគេ ។

ប្រុញ: វរសេនាធំអីគេ?

ហាក់: វរសេនាធំដូចជាកងទ័ពមានវរសេនាធំពាកងវរៈតូច អីចឹងមានកងវរសេនាធំគេគ្រប់គ្រង យើងសំរាប់ដឹកស្បៀងឲ្យគេ បើកឡាន ។

ប្រុញ: នៅពេលដែលបែកសម័យពន្ធ្នាំហ្នឹងក្លាមពូរត់ទៅព្រៃ ឬម៉េច?

ហាក់: ព្រៃ ។

ប្រុញ: ព្រៃអីគេ?

ហាក់: ព្រៃឡង់ ហើយបានមកភ្នំ ។

ប្រុញ: ពីណាអ្នកនាំពូរត់ចូល?

ហាក់: អត់ដឹងមុខ ស្រេចគេទៅណាទៅៗ បែកបាក់គ្នាអស់ ។

ប្រុញ: ពេលហ្នឹងមេដែលធំរបស់ពូឈ្មោះអីគេ?

ហាក់: តាសារឿន ។

ប្រុញ: ពូបាននៅជាប់ជាមួយគាត់?

ហាក់: អត់ទេ អត់មានជាប់ទេ គ្រាន់តែគាត់គ្រប់គ្រងពីលើ ខ្ញុំនៅក្រោមទៅទៀត ក្រោមមកតាមវរសេនាតូចទៀត ហើយបាននាំគ្នាដើរបេះតែរាវរកគ្នាអីចឹង មកឃើញគ្នានៅលើភ្នំ ។

ប្រុញ: ជួបតាសារឿន ញឹកទេកាលហ្នឹង?

ហាក់: អត់សូវជួបទេ អត់ដែលជួបទេ ជួបតែមេៗ មេៗគេទៅជួប យើងតូចតាចគេម៉េចឲ្យជួបបានជួបមេៗ កូនៗអត់បាន ។

ប្រុញ: ចូលព្រៃឡង់ហើយមកណាទៀតពូ?

ហាក់: ឡើងមកលើភ្នំ ។

ប្រុញ: ឡើងលើភ្នំអីគេ?

ហាក់: ភ្នំដងរែក ។

ប្រុញ: មកហ្នឹងធ្វើអី?

ហាក់:	មកកន្លែងបន្អែករកមេ ដើម្បីមានអីហូប ព្រោះបែកខ្ចាត់ខ្ចាយគ្នាអត់មានអីហូប ដល់អីចឹង ម្នាក់ៗស្វែងរកមេ មានបាយ មានអង្ករហូប ។

ប្រុញ:	មកៗជួបពីណាគេ?

ហាក់:	មុនដំបូងជួបកន្លែងគេទទួលខុសត្រូវ ទទួលកងទ័ពដែលរត់ខ្ចាត់ខ្ចាយគេប្រមូល ។

ប្រុញ:	គាត់ឈ្មោះអីគេ? អ្នកដែលមកនេះហ្នឹង?

ហាក់:	អ្នកគ្រប់គ្រងឈ្មោះពូដុក ។

ប្រុញ:	គាត់មកគ្រប់គ្រងនៅ?

ហាក់:	គាត់ខាងសេដ្ឋកិច្ចទទួលកងទ័ពមកពីក្រោមហ្នឹង ។

ប្រុញ:	នៅមុំ៣?

ហាក់:	បាទ! មុំ៣ ។

ប្រុញ:	អីចឹងពូនៅហ្នឹងចាប់ពីឆ្នាំណាមក?

ហាក់:	នៅហ្នឹង៨០ ។

ប្រុញ:	៨០មកដល់មុំ៣?

ហាក់:	មុំ៣ហ្នឹង៨០តែម្តង ។

ប្រុញ:	អីចឹងដុក ហ្នឹងគាត់កាន់ខាងសេដ្ឋកិច្ច ចុះពីណាកាន់ខាងយោធា?

ហាក់:	យោធាហ្នឹងខាងកងទ័ពផ្សេង ខាងសេដ្ឋកិច្ចគេអ្នកនៅក្រោយគេដឹងតែខាងសេដ្ឋកិច្ចទេទទួល ខាងដឹកស្បៀងមក គេអត់មានគិតរឿងយោធា យោធាផ្សេង ។

ប្រុញ:	អីចឹងដោយសារមុនហ្នឹងពូធ្លាប់កាន់សេដ្ឋកិច្ចត្រូវទេពូ?

ហាក់:	បាទ?

ប្រុញ:	ឧទាហរណ៍ថាពូកាន់ខាងនេសាទ អីចឹងមកជួបគេឲ្យមកជួបខាងសេដ្ឋកិច្ច?

ហាក់:	អត់ទេ ដល់ហើយយើងមកនៅតាមកន្លែងយើងវិញ ព្រោះអីយើងបែកបាក់គ្នាហើយ យើងមកវិញលែងមានកន្លែងរកត្រីហើយ អស់កន្លែងរកត្រី កាលពីមុននៅតាមទន្លេមាន កន្លែងរកត្រី ។

ប្រុញ:	កាលហ្នឹងពូរកត្រីនៅណាវិញ?

ហាក់:	រកត្រីទន្លេសេកុង ។

ប្រុញ:	ធម្មតាត្រីមានច្រើន មានជនជាតិចាមរកទេ?

ហាក់:	ទៅនោះអត់មានទេ មានតែលាវ ហើយនិងជនជាតិភាគតិចគេរក ដូចជាចារាយ, ទំពួន, ភ្នងគេរក ។

ប្រុញៈ រកទៅអត់អី?

ហាក់ៈ អត់អី ។

ប្រុញៈ ជួបគ្នាអត់អី?

ហាក់ៈ អត់អីទេ យើងរកបានយករបស់យើង គេរកបានយករបស់គេ ។

ប្រុញៈ ចុះវៀតណាមមានមកហ្នឹងទេ?

ហាក់ៈ អត់ទេ វៀតណាមគេនៅប្រទេសគេ មានមករកត្រីណា យើងនៅតំបន់ដែលសុខសាន អត់មានជិតគ្នា ។

ប្រុញៈ ប្តូកហ្នឹងកាលហ្នឹងមានជនជាតិវៀតណាមមកដល់ហ្នឹងទេ?

ហាក់ៈ អត់ទេ ។

ប្រុញៈ ៨០ ?

ហាក់ៈ អត់មានមកដល់ហ្នឹងទេ ។

ប្រុញៈ ជនជាតិចាមអត់ដែរ?

ហាក់ៈ ជនជាតិចាម, វៀតណាម អត់មានទេ មានតែចារាយ, ទំពួន, ក្រឹងមាន ហើយលាវ ។

ប្រុញៈ ពេលហ្នឹងមានធ្លាប់ប៉ះទង្គិចជាមួយជនជាតិចារាយអត់?

ហាក់ៈ អត់ទេ រកស៊ីជាមួយគ្នាអត់មានប៉ះអី ។

ប្រុញៈ ពូមានដឹងរឿងថាសម្លាប់ជនជាតិចាម?

ហាក់ៈ អត់ដឹង ។

ប្រុញៈ ជនជាតិវៀតណាម?

ហាក់ៈ អត់ដឹងទេ អត់ដែលជួប ចាម, វៀតណាមអត់ដែលជួបទេ ។

ប្រុញៈ ក្រោយ៧៩-៨០ ?

ហាក់ៈ អត់ដែលជួប ។

ប្រុញៈ ចុះមុនឆ្នាំ៧៥ ?

ហាក់ៈ អត់ដែលជួប ខ្ញុំនៅក្រោយអត់ដែលជួបទេ ។

ប្រុញៈ ពូមានដែលដឹង គេមាននិយាយពីរឿងការសម្លាប់ជនជាតិចាម, ជនជាតិវៀតណាម?

ហាក់ៈ អត់ អត់ដែលលឺសូរនិយាយ ការងារគេអត់ដែលឲ្យយើងដឹងទេ ។

ប្រុញៈ ខាងពូខាងសេដ្ឋកិច្ច?

ហាក់ៈ យើងខាងសេដ្ឋកិច្ចរកម្ហូប គិតតែខំរក ខំដាក់បង្កៃ, សន្ទូច, ម៉ង គិតខាងហ្នឹងទៅ ។

ប្រុញៈ ពូមកដល់នៅមុំពាប៉ុន្មានឆ្នាំ?

ហាក់៖	មិនដឹងប៉ុន្មានឆ្នាំ រហូតដល់៩៣ ។

ប្រុញ៖	៩៣ បានពូចុះមកនៅណាវិញ?

ហាក់៖	ចុះមកនៅ នៅនេះអន្លង់វែង ។

ប្រុញ៖	អន្លង់វែងហើយបានមកភូមិនេះ?

ហាក់៖	បាទ!

ប្រុញ៖	នៅអន្លង់វែងកាលហ្នឹងពីណាអ្នកគ្រប់គ្រងពូ?

ហាក់៖	តាសារឿនដដែល ។

ប្រុញ៖	តាសារឿន ដល់ពេលមកនេះពីណាគេ?

ហាក់៖	តាសារឿន ហ្នឹងដែរ ដល់តាម៉ុក ចាប់តាសារឿនទៅ បានផ្តាច់ខ្លួន ។

ប្រុញ៖	ម៉េចបានតាម៉ុក ចាប់តាសារឿន អីចឹង?

ហាក់៖	មិនដឹងម៉េចទេរឿងខាងគេមេៗ ខ្ញុំអត់ដឹង អត់ដឹងគេចាប់បញ្ហាអី ។

ប្រុញ៖	ពូខ្ញុំសុំសួរពូរឿងតុលាការវិញម្តង ពូដែលដឹងតុលាការកាត់ទោសមេដឹកនាំធំៗខ្មែរក្រហម?

ហាក់៖	អត់ដឹងទេ ។

ប្រុញ៖	ខាងអ្នកតុលាការគេអត់ដែលចុះមកដល់នេះទេ?

ហាក់៖	អត់ដែលដឹង ។

ប្រុញ៖	រាល់ថ្ងៃតុលាការគេកំពុងកាត់ទោសមេដឹកនាំជាន់ខ្ពស់ធំៗ រាល់ថ្ងៃជនជាប់ចោទ នួន ជា គាត់ជាងអនុលេខាបក្សសម័យហ្នឹង ហើយ ខៀវ សំផន គាត់ជាប្រមុខរដ្ឋ អីចឹងរាល់ថ្ងៃ គេកំពុងកាត់ ។ មួយទៀតខ្ញុំចង់សួរយោបល់ពូថាតើបើក្នុងករណីកាត់អីចឹងពូយល់ឃើញ ម៉េចដែរ?

ហាក់៖	ខ្ញុំអត់សូវដឹងដែរខាងផ្នែកនយោបាយអត់សូវដឹងទេខ្ញុំ ។

ប្រុញ៖	នេះមិនមែនជារឿងនយោបាយទេ ជារឿងការស្វែងរកយុត្តិធម៌ជូនអ្នកដែលស្លាប់នៅក្នុង សម័យខ្មែរក្រហមវិញ តើនាំគាត់មកកាត់ទោសអីចឹងពូយល់ឃើញម៉េចដែរ?

ហាក់៖	ខ្ញុំអត់យល់ទេខ្ញុំ អត់សូវយល់តែម្តង ។

ប្រុញ៖	ចុះមួយទៀតចង់សួរថា ជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ហើយរាល់ថ្ងៃគាត់អាច ក្លាយជាមេធាវី ការពារជនជាប់ចោទ ដែលគេចាត់តាំងគាត់ឲ្យមកការពារជនជាប់ចោទ សម័យខ្មែរក្រហមដែលបានសម្លាប់មនុស្ស ឧទាហរណ៍ ។ តើពូយល់ឃើញថាការដែលគាត់ ធ្វើមេធាវីហើយមកការពារជនជាប់ចោទ តើគាត់អាចការពារជនជាប់ចោទមានប្រសិទ្ធភាព ទេ ព្រោះគាត់ធ្លាប់ជាជនរងគ្រោះក្នុងសម័យហ្នឹងដែរ?

ហាក់៖ បើសិនជាគាត់ជាជនរងគ្រោះដែល ការពារធ្វើមេធាវីបាន ព្រោះគាត់រងគ្រោះដែរ ខ្ញុំថាធ្វើមេធាវីបាន ព្រោះគាត់អ្នករងគ្រោះដែរ ហ្នឹងតាមគំនិតខ្ញុំទេ ។

ប្រុញ៖ ខ្ញុំគ្រាន់តែចង់សួរថា ឧទាហរណ៍ថាគាត់ជាមេធាវីហើយ ប្រកបការងារការពារជនជាប់ចោទផ្សេងៗ ហើយឥឡូវគេមកចាត់តាំងឲ្យមកការពារជនសង្ស័យ ឬជនជាប់ចោទដែលត្រូវមកកាត់ទោសនៅសាលាក្តីខ្មែរក្រហមហ្នឹងដែរ ។

ហាក់៖ តែពីមុនគាត់ការពារជនជាប់ចោទហើយ ។

ប្រុញ៖ គាត់ធ្លាប់ការពារធម្មតា ពីមុនធម្មតា ប៉ុន្តែគាត់ធ្លាប់ជាជនរងគ្រោះសម័យខ្មែរក្រហមដែរ ស្រាប់តែគេឲ្យគាត់មកការពារឲ្យជនជាប់ចោទដែលគាត់ធ្លាប់ជាអ្នកប្រព្រឹត្តិខុស ក្នុងសម័យខ្មែរក្រហម ។

ហាក់៖ គ្រាន់តែការពារ?

ប្រុញ៖ បាទ! ការពារ តែបានន័យថាធ្វើសកម្មភាពយ៉ាងម៉េចដើម្បីការពារកូនក្តីរបស់ខ្លួន អីចឹងចង់សួរការចាត់តាំងមេធាវីដែលជាកូនជនរងគ្រោះ ហើយមកការពារ?

ហាក់៖ មកការពារមេ ។

ប្រុញ៖ ឧទាហរណ៍ថាក្រុមកគ្រួសារគាត់មានការរងគ្រោះដោយសាររបបខ្មែរក្រហមអីចឹង ឥឡូវគាត់មេធាវីមកការពារតែមកការពារជនជាប់ចោទ ។ ធម្មតាការពារជនជាប់ចោទគឺធ្វើសកម្មភាពយ៉ាងម៉េចដើម្បីឲ្យកូនក្តីរបស់ខ្លួនរួចខ្លួន ។

ហាក់៖ ការពិតកូនក្តីហ្នឹងខុស?

ប្រុញ៖ បាទ! ធម្មតាគេយល់ថាកូនក្តីរបស់គាត់ជាអតីតកម្មាភិបាលធំៗសម័យខ្មែរក្រហម?

ហាក់៖ គាត់យល់ថាគាត់ជាមេពីមុនមកខំការពារឲ្យរួចខ្លួន?

ប្រុញ៖ ចង់និយាយថាតើក្នុងករណីដែលមេធាវី ធ្លាប់ជាកូនរបស់ជនរងគ្រោះនៅសម័យខ្មែរក្រហមឥឡូវឲ្យមកការពារជនដៃដល់ដែលធ្លាប់ធ្វើឲ្យក្រុមគ្រួសាររបស់ខ្លួនរងគ្រោះ តើការចាត់តាំងមេធាវីប្រភេទអីចឹងអាចការពារកូនក្តីបានប្រសិទ្ធិភាពទេ?

ហាក់៖ ខ្ញុំថាអត់ប្រសិទ្ធិភាពទេតាមគំនិតខ្ញុំ ។

ប្រុញ៖ ម៉េចអីចឹងពូ?

ហាក់៖ ចុះការពារដោយអត់យុត្តិធម៌ ។

ប្រុញ៖ ការពារដោយអត់យុត្តិធម៌?

ហាក់៖ ចុះគាត់ពីមុនធ្លាប់ធ្វើបាបហើយទៅការពារវិញ ធ្លាប់ធ្វើមេហើយ ការពារម្នាក់ហ្នឹងខ្លាច ព្រោះពីមុនមកមានឥទ្ធិពលដល់គាត់ ដល់អីចឹងចេះតែការពារ ជួយសំរាលទោស សំរាលទុក្ខអីចឹងក៏មានព្រោះធ្លាប់ធ្វើមេ ។

ប្រុញ៖ មិនមែនមេទេពូ ។ ឧទាហរណ៍ថាមេធាវីហ្នឹងគាត់ជាប្រជាជនសាមញ្ញធម្មតាទេដែលរស់នៅក្នុងសម័យខ្មែរក្រហម ហើយគាត់រងគ្រោះដោយសាររបបខ្មែរក្រហម ។

ហាក់៖ មិនមែនមេទេអី?

ប្រុញ៖ គាត់មិនមែនមេទេ គាត់ប្រជាជនធម្មតាទេ ។

ហាក់៖ តែគាត់អ្នករងគ្រោះ?

ប្រុញ៖ បាទ! រងគ្រោះសម័យខ្មែរក្រហម ឧទាហរណ៍គាត់បាត់បង់ក្រុមគ្រួសារ ។

ហាក់៖ បាត់បងប្អូនក្រុមគ្រួសារគេធ្វើបាប ។

ប្រុញ៖ ឥឡូវដល់សម័យនេះគេចាប់ផ្ដើមកាត់ទោសមេដឹកនាំខ្មែរក្រហម គឺគេចាត់តាំងគាត់ដែលធ្លាប់ជនរងគ្រោះពីមុនឲ្យមកការពារមេដឹកនាំខ្មែរក្រហម ។ ចង់សួរថាធម្មតាគាត់មានអារម្មណ៍ខឹងអត់ មានអារម្មណ៍គុំគួនជាមួយមេដឹកនាំខ្មែរក្រហមអត់? បើសិនជាគាត់មានការគុំគួនអីចឹងមែន វាអាចប៉ះពាល់ដល់មេធាវីដែលការពារកូនក្ដីរបស់ខ្លួនធ្វើម៉េចឲ្យមានប្រសិទ្ធិភាព ប៉ុន្តែដល់ពេលគាត់ជាជនរងគ្រោះអីចឹង តើគាត់អាចការពារបានទេ?

ហាក់៖ បើសិនជាគាត់មានអារម្មណ៍ដូចគាត់និយាយម៉ិញការពារបាន ។

ប្រុញ៖ ការពារបានហើយ ចង់និយាយថាគាត់អាចធ្វើការឲ្យអស់លទ្ធិភាពដើម្បីការពារកូនក្ដីរបស់ខ្លួនទេ?

ហាក់៖ ហ្នឹងវាអត់សូវយល់ដែរអីចឹង អត់ច្បាស់លាស់ដែរ ខ្ញុំមិនដែលចូលប្រឡូកការងារអីចឹង១ មិនសូវយល់ មិនសូវមានអ្នកបង្រៀនពីផ្នែកហ្នឹងផង ។

ប្រុញ៖ ខ្ញុំនិយាយម៉េចឲ្យ ឧទាហរណ៍ថាជនជាប់ចោទ នួន ជា ឧទាហរណ៍ នួន ជា គាត់សម័យខ្មែរក្រហមគាត់មេដឹកនាំធំ ដែលធ្វើឲ្យប្រជាជនស្លាប់ ហើយមេធាវីមានក្រុមគ្រួសារគាត់បានស្លាប់ក្នុងសម័យខ្មែរក្រហមហ្នឹង អីចឹងគាត់អាចចាត់ទុកជាជនរងគ្រោះមួយ ប៉ុន្តែស្រាប់តែគាត់គេចាត់តាំងឲ្យការពារ នួន ជា ឧទាហរណ៍ថាអីចឹងចុះ ។ យើងឧទាហរណ៍ឈ្មោះបុគ្គលជាក់ស្ដែង អីចឹងសួរថាតើមេធាវីហ្នឹងគាត់អាចធ្វើការឲ្យមានប្រសិទ្ធិភាពក្នុងការការពារនួន ជា អត់? ព្រោះធម្មតាគាត់មានក្រុមគ្រួសាររងគ្រោះ ព្រោះអាចគិតថាគាត់គុំគួន គាត់បាត់បង់ក្រុមគ្រួសារដែរ តែវាជាឧទាហរណ៍ទេ ខ្ញុំមិនមែនលើកករណីនួន

ជា ហ្នឹងទេ ឧទាហរណ៍ផ្សេងៗ អីចឹងគំនិតលោកពូនៅពេលដែលជនរងគ្រោះហើយចាត់តាំងឲ្យមកការពារជនជាប់ចោទ តើគាត់អាចការពារបានមានប្រសិទ្ធិភាពអត់?

ហាក់: ខ្ញុំអត់ហ៊ានធានាដែរ មិនដឹងអ្នកដែលជាមេធាវីហ្នឹងម៉ឺងម៉ាត់ឬមិនម៉ឺងម៉ាត់ ហ្នឹងលើមេធាវី បើធ្វើធូររលុងការពារអត់បាន បើតឹងតែងការពារបាន ។

ប្រុញ: ប៉ុន្តែលោកពូគិតថាមេធាវីអាចមានភាពម៉ឺងម៉ាត់ក្នុងការការពារដែរ?

ហាក់: ខ្ញុំថាម៉ឺងម៉ាត់ការពារបាន បើមេធាវីធូររលុងឬមួយក៏ឆាប់យល់យោគហ្នឹងការពារអត់បានដែរ ។

ប្រុញ: ប៉ុន្តែសំរាប់ពូមេធាវីអាចយល់យោគការពារអត់បានដែរ?

ហាក់: មិនអាចយោគយល់ទេ កាត់តាមច្បាប់ ហ្នឹងបើយល់ញាតិឃ្លាតច្បាប់ហើយ បើឃ្លាតច្បាប់អត់អាចការពារបានទេ ។

ប្រុញ: ឧទាហរណ៍គាត់អតីតជាជនរងគ្រោះ ធម្មតាមេធាវីត្រូវការពារហើយ ប៉ុន្តែនៅពេលគាត់ជាជនរងគ្រោះ តើគាត់អាចអនុវត្តន៍កាតព្វកិច្ចក្នុងការការពារឲ្យមានប្រសិទ្ធិភាពទេ?

ហាក់: បាន គាត់ការពារបាន តាមខ្ញុំយល់ បាន ។

ប្រុញ: គ្រាន់ជាទស្សនៈរបស់ពូ ពូយល់ឃើញថាគាត់ខំប្រឹងប្រែងការពារជនជាប់ចោទអត់?

ហាក់: គាត់ខំហើយព្រោះពីមុនគាត់រងទុក្ខវេទនាដោយសារអ្នកគំរាមកំហែងគាត់ ធ្វើបាបគាត់ដែរ

ប្រុញ: ពាក្យថាខំការពារនេះ ធម្មតាគាត់ការពារយ៉ាងម៉េចដួយ ឲ្យកូនក្តីរបស់គាត់ជាអតីតមេដឹកនាំខ្មែរក្រហមរួចផុតពីការទទួលខុសត្រូវ មិនមែនជាលក្ខណៈការពារ?

ហាក់: ការពារឲ្យរួចផុតពីការកាត់ក្តី?

ប្រុញ: បាទ!

ហាក់: ការពារអត់បានទេ ។

ប្រុញ: ម៉េចអីចឹង?

ហាក់: ព្រោះអីតាមច្បាប់ បើនិយាយពីច្បាប់ ការពារអត់បាន ឲ្យផុតពីការកាត់ទោសអត់បានទេ ព្រោះអីនិយាយច្បាប់ ព្រោះអីអ្នកហ្នឹងត្រូវកាត់ទោស ការពារអត់កាត់ទោសវិញអត់បានទេ ។

ប្រុញ: មុននឹងកាត់ទោសទាល់តែមានការការពារសិន ទាល់តែគាត់មើលទៅ បង្ហាញសមត្ថភាពគាត់អាចការពារបាន មិនបាន បានកាត់ទោស?

ហាក់: បានកាត់ទោស?

ប្រុញៈ ព្រោះអីវាអាចគាត់មានសមត្ថភាពខ្ពស់អាចការពារជនជាប់ចោទ រួចផុតពីការកាត់ទោស គាត់ខំប្រឹងប្រែង គាត់បង្ហាញភស្តុតាង ។

ហាក់ៈ ទាល់បង្ហាញការពិតទាំងអស់បានគេជឿ បើមិនបង្ហាញការពិត អ៊ីៗដែលធ្វើពីមុនមកអត់បានទេ ។

ប្រុញៈ ហ្នឹងទាមទារការប្ដេជ្ញាខ្ពស់របស់មេធាវីដែរ ។

ហាក់ៈ បាទ!

ប្រុញៈ មេធាវីមានឆន្ទះការពារកូនក្ដីរបស់ខ្លួនឲ្យខ្លាំងតែម្ដងវាអាច តែក្នុងករណីដែលគាត់ជាជនគ្រោះតើគាត់មានឆន្ទះខ្ពស់ក្នុងការការពារកូនក្ដីគាត់ដែលអត់?

ហាក់ៈ ការពារ តាមខ្ញុំយល់ការពារមិនផុតទេ បើយើងបានប្រព្រឹត្តិបានធ្វើមែន ការពារអត់ផុតទេ បើយើងអត់ធ្វើការពារបាន តែបើយើងធ្វើហើយការពារមិនបានទេ ឲ្យចៀសផុតពីការប្រល័យពូជសាសន៍ចុះ ជំនាន់ហ្នឹងប្រល័យពូជសាសន៍ពិតមែន ស្លាប់មនុស្សរាប់ពាន់ ម៉ឺននាក់ យើងទៅការពារយ៉ាងម៉េចបាន ទៅថាឲ្យអត់សម្លាប់ម៉េចបាន បើសម្លាប់មែន អីចឹងទៅការពារម៉េចបាន ការពារកូនក្ដីរបស់គាត់ឲ្យផុតពីការជាប់ទោស ជាប់ចោទហ្នឹងអត់បានទេ ត្រូវតែមានតែម្ដង ។

ប្រុញៈ ពូនិយាយចាប់អារម្មណ៍ប្រល័យពូជសាសន៍ ហេតុអីបានពីថាប្រល័យពូជសាសន៍?

ហាក់ៈ ចុះជំនាន់ហ្នឹងខាងរដ្ឋាភិបាលបាននិយាយថា ជំនាន់ប៉ុល ពត សម្លាប់ខ្មែរខ្លួនឯង មិនសម្លាប់ខ្មែរប្រល័យពូជសាសន៍ខ្មែរខ្លួនឯង មនុស្សស្លាប់រាប់ពាន់ ម៉ឺន សែន នាក់នៅក្នុងប្រទេសកម្ពុជា មិនប៉ុល ពត ដោយសារស្នាដៃប៉ុល ពត ។ ប៉ុល ពត អត់ទៅសម្លាប់ផ្ទាល់មែនតែដៃជើងប៉ុល ពត ។ ឧទាហរណ៍ថាឲ្យនួន ជា ៗចំអីចឹង បញ្ជាមកមានអ្នកណាក្រោមមកបញ្ជាតទៅទៀត សូម្បីតែឪពុកខ្លួនឯងក៏ហ៊ានសម្លាប់ដែរ ដើម្បីរួចខ្លួនឯង ។ បងត្រូវប្អូនសម្លាប់ បើមិនសម្លាប់គេសម្លាប់ អីចឹង ត្រូវតែសម្លាប់ដើម្បីរួចខ្លួន ប្អូនក៏សម្លាប់បង បងក៏សម្លាប់ខ្លួន ឲ្យតែគេចាត់តាំងថាត្រូវសម្លាប់ ត្រូវតែសម្លាប់ ។

ប្រុញៈ ពូមុនឆ្នាំ៧៥បានដឹង ឬមានពីណានិយាយថាមានការបញ្ជាឲ្យសម្លាប់ទាហានលន់ នល់ ឬក៏ជនជាតិវៀតណាម ឬជនជាតិចាម?

ហាក់ៈ អត់ដឹង ខ្ញុំអត់សូវដឹងនៅតូចពេក ។

ប្រុញៈ ពូកាលហ្នឹងអាយុប៉ុន្មានឆ្នាំ?

ហាក់ៈ អាយុ១៣-១៤ឆ្នាំ ។ ខ្ញុំគិតតែគេឲ្យនៅនីរសាគេប្រើទៅនោះ ចេះតែទៅ គេមានសំបុត្រអីឲ្យខ្ញុំមក ខ្ញុំយកទៅឲ្យគេនោះទៀត នៅនីរសា ។

ប្រុញៈ ក្រោយឆ្នាំ៧៩ពូមានដែលលឺគេនិយាយរឿងអីចឹង? រឿងគេសម្លាប់?

ហាក់ៈ អត់ដែលលឺសូរគេនិយាយរឿងសម្លាប់វៀតណាម សម្លាប់ចាម អត់ដែលលឺសូរ ។

ប្រុញៈ ឆ្នាំ៧៩-៨០ ពូអត់ដែលជួបអ្នកធំណាដែលគេនិយាយពីរឿងហ្នឹង?

ហាក់ៈ ខ្ញុំអត់ដែលបានទេ ខ្ញុំកំសត់ៗណាស់ នៅរកត្រី បាញ់សត្វ ដាច់ឡែកតែ៤-៥នាក់ គេទៅណាទៅៗ ខ្ញុំត្រីបានមកយកទៅឲ្យ ជួនកាលគេមកយកដល់កន្លែង យើងគិតតែពីរកត្រីនៅក្នុងបឹង ក្នុងទន្លេ មានទូក ។

ប្រុញៈ មានគេមកយក?

ហាក់ៈ គេមកយកហើយគេត្រូវការសាច់ព្រៃ យើងដើរឆ្នុះ បាញ់តាមព្រៃ ។

ប្រុញៈ អីចឹងពូចូលជាមួយរដ្ឋាភិបាលឆ្នាំណាដែលពូ?

ហាក់ៈ ផ្តាច់ខ្លួនកៅប៉ុន្មានខ្ញុំភ្លេចហើយ ៩៥ កៅប៉ុន្មានទេភ្លេច ។

ប្រុញៈ ពីណាគេនាំពូឲ្យមកចូលរួមជាមួយរដ្ឋាភិបាលវិញ?

ហាក់ៈ កាលហ្នឹងមុននឹងផ្តាច់ខ្លួនហ្នឹងពួកគេខាងនោះហៅពួកខ្ញុំ ដូចថាតស៊ូតកូនតចៅ ពួកខ្ញុំខាងនេះថាអត់ទេ ចូលជាមួយរដ្ឋាភិបាល បើចង់បានធ្វើធំបោះឆ្នោត ដល់ហើយគេខាងនោះគេអត់ចូលទេ ពួកខ្ញុំខាងនេះផ្តាច់ខ្លួនមួយកំណាត់ចូលខាងរដ្ឋាភិបាលដើម្បីបញ្ចប់សង្រ្គាម ហើយខាងនោះខាងអន្លង់វែងគេអត់ផ្តាច់ទេ ដល់អីចឹងខាងខ្ញុំនេះក៏ទាក់ទងជាមួយរដ្ឋាភិបាលហ្នឹងទៅនៅវ៉ៃគ្នាទៀត វ៉ៃជាមួយខាងអន្លង់វែង ។

ប្រុញៈ ខាងអន្លង់វែងកាលហ្នឹងពីណាគេគ្រប់គ្រង?

ហាក់ៈ តាម៉ុក ។

ប្រុញៈ ហើយខាងពូ?

ហាក់ៈ តាសារឿន ដឹងតាសារឿន ចង់ចរចារជាមួយរដ្ឋាភិបាលដើម្បីបញ្ចប់សង្រ្គាម ចាប់តាសារឿន មេធំទៅសម្លាប់ សម្លាប់ចោល ។

ប្រុញៈ សម្លាប់ចោលក្នុងឆ្នាំណា?

ហាក់ៈ មិនដឹងឆ្នាំប៉ុន្មានខ្ញុំភ្លេចហើយ ។ មុននឹងចប់សង្រ្គាមហ្នឹង ដល់ក្រោយមកទៀតខ្ញុំអត់បានធ្វើអីទាំងអស់ទៀត ខ្ញុំគេឲ្យបង្រៀនក្មេងតាំងពី៩៤-៩៥រហូតដល់រាល់ថ្ងៃហ្នឹង ។

ប្រុញៈ អីចឹងពូរាល់ថ្ងៃបង្រៀនក្មេង?

ហាក់ៈ បង្រៀនក្មេង ។

ប្រុញៈ សាលានៅណា?

ហាក់ៈ បង្រៀននៅទំនប់អភិវឌ្ឍន៍ ។

ប្រុញៈ ឆ្ងាយដែរ?

ហាក់ៈ ៤គីឡូកន្លះពីនេះទៅ។ បើនិយាយជំនាន់ជ្រើសគ្រោមខ្ញុំក៏អត់ដែលទៅច្បាំងនឹងគេដែរ មិនដែលបានទេ នៅខាងក្រោយ ខាងនីរសា គេវៃគ្នាមុខខ្ញុំទៅក្រោយ ខ្ញុំនៅក្រោយរហូត។

ប្រុញៈ នៅខាងសេដ្ឋកិច្ចគ្រប់គ្រង?

ហាក់ៈ សេដ្ឋកិច្ចហ្នឹងមិនមែនចិញ្ចឹមទាំងកងពលទេ សេដ្ឋកិច្ចហ្នឹងគេឲ្យចិញ្ចឹមតែវរសេនាតូច១០០នាក់ យើង៤-៥នាក់សំរាប់ផ្គត់ផ្គង់គេ ហើយការងារអ៊ីៗផ្ទៃក្នុងរបស់គេខ្ញុំអត់ដឹងទាំងអស់ គេដឹងតែឲ្យយើងខិតខំរកម្ហូបឲ្យគេ។

ប្រុញៈ អរគុណច្រើនពូ សុខសប្បាយ រំខានពូ។

ហាក់ៈ បាទ!

ចប់